**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ០៦៤/០៦

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ

## សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរ ឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងលិខិត លេខ ១៧៧៦/ស.ជ.ណ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**ប្រការ ១** : បង្កើតក្រុមប្រឹក្សាកីឡាមួយមានឈ្មោះថា **ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ** ដែលមានអក្សរកាត់

ទីស្តីការក្រសួងការពារជាតិ ទូរស័ព្ទ-ទូរសារ : (៨៥៥) ០២៣ ៨៨៣២៧៤ E.Mail : Minadef@camnet.com.kh

16 MAR 2006

ជាភាសាខ្មែរ ក.ប.ក.ខ.ភ.ម ជាអក្សរឡាតាំង **C.S.R.C.A.F.** ( Council Sport of Royal Cambodian Armed Forces ) ។

**ប្រការ ២** : សមាសភាព នៃក្រុមប្រឹក្សាអង្គការកីឡាកងយោធពលខេមរភូមិន្ទ រួមមាន :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ុឺង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា សារិន** | មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក | ជាអនុប្រធាន |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឥត សារ៉ាត់** | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការហ្វឹកហ្វឺន | ជាអនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ត្រី | **តែម ម៉ុន** | នាយករងទីចាត់ការហ្វឹកហ្វឺន និងជាប្រធានមជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សំ វណ្ណថន** | អគ្គលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ុំ សំណាង** | អគ្គនាយក អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ | ជាសមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចៅ តិរុណ** | អគ្គនាយក អគ្គនាយកដ្ឋាន សម្ភារៈបច្ចេកទេស | ជាសមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **មាស សារ៉ាន** | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា | ជាសមាជិក |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ឹង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | ជាសមាជិក |
| ១០-ឯកឧត្តម ឧត្តមនាវីឯក | **អ៊ុង សំខាន់** | មេបញ្ជាការកងទ័ពជើងទឹក | ជាសមាជិក |
| ១១-ឯកឧត្តមឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **មាស សំអុល** | នាយក នាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ១៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជាំ ឡុត្ថី** | នាយរងសេនាធិការចំរុះនិងជានាយកទីចាត់ការបុគ្គលិក | ជាសមាជិក |

**ប្រការ ៣** : ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ មានភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រង និងដឹកនាំ ដល់បណ្តាសមាគមន៍ និងក្លឹបកីឡានានា ក្នុងកងយោធពលខេមរភូមិន្ទ ។
- រៀបចំក្រុមកីឡាកងយោធពលខេមរភូមិន្ទ ចូលរួមប្រកួតជាលក្ខណៈ ជាតិ-អន្តរជាតិ ។
- សហការជាមួយស្ថាប័នកីឡាជាតិ និងស្ថាប័នកីឡាអន្តរជាតិ ផ្លាស់ប្តូរដកបទពិសោធន៍ បណ្តុះបណ្តាល និងស្វែងរកប្រភពក្នុងការទ្រទ្រង់ កសាងកីឡាកងយោធពលខេមរភូមិន្ទ ។
- មានសិទ្ធិចូលរួមប្រជុំរាល់វេទិកាកីឡាទាំងអស់ ដែលពាក់ព័ន្ធជាមួយកងយោធពលខេមរភូមិន្ទ ។
- ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទមានសិទ្ធិតែងតាំងគណៈកម្មការប្រតិបត្តិ និងអគ្គលេខាធិការដើម្បីដំណើរការរាល់ភារកិច្ចរបស់ខ្លួន ។
- មានសិទ្ធិបង្កើតគណៈកម្មការក្នុងពេលដំណើរការប្រកួត និងពិធីនានា របស់កីឡាកងយោធពលខេមរភូមិន្ទ ព្រមទាំងដោះស្រាយនូវរាល់ភាពអសកម្មទាំងឡាយ ។

- ក្រុមប្រឹក្សានេះមានសិទ្ធិប្រើប្រាស់ត្រា និងរូបសញ្ញារបស់ខ្លួនសំរាប់ដំណើរការលើកិច្ចការរដ្ឋបាលនានា ។

**ប្រការ ៤** : អគ្គមេបញ្ជាការ ខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក ទីចាត់ការ ហ៊្វឹកហ្វឺន នាយក នាយកដ្ឋាន ប្រធាន ស្ថាប័ន មេបញ្ជាការ កងឯកភាពដែលមានការពាក់ព័ន្ធ និងសមាសភាពក្នុងប្រការ២ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយឧ.ផ្កាយមាសេ៥ ទៀ-បាញ់ នាយឧ.ផ្កាយមាស៤.ញឹក-ប៊ុនឆៃ

**ចម្លងជូន**

- ថ្នាក់ដឹកនាំក្រសួងការពារជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ទីប្រឹក្សាក្រសួងការពារជាតិ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ

"ដើម្បីជូនជ្រាប"

- អគ្គបញ្ជាការដ្ឋាន ខេមរភូមិន្ទ
- ស្ថាប័នកីឡាជាតិ
- ដូចប្រការ ៤

(ដើម្បីជ្រាប និងសហការអនុវត្ត)

- ឯកសារ- កាលប្បវត្តិ